# ដំណើរទស្សនកិច្ចទៅកាន់ផ្ទះសិក្ខាកាមនៅពេលចុះទៅធ្វើបទសម្ភាសន៍ក្នុងស្រុក

ក្រុមហ៊ុនឧស្សាហកម្មតាកាគីបានចុះធ្វើបទសម្ភាសន៍ផ្ទាល់នៅក្នុងស្រុក។ ក្រុមគ្រួសារសិស្សបានអញ្ជើញលោកប្រធាន តាកាគី ហ៊ីដេយូគី ធ្វើដំណើរទស្សនកិច្ចនេះទៅកាន់ផ្ទះពួកគេផងដែរ ។

ក្រុមហ៊ុនឧស្សាហកម្មតាកាគី
ប្រភេទការងារ : ចាក់ពុម្ព (ប្រភេទសំណង់)
សិក្ខាកាម : ៥ នាក់ (ជនជាតិវៀតណាម)



នៅផ្ទះរបស់សិក្ខាកាមរីន/ (រាប់ពីឆ្វេង) អ្នកបកប្រែ រីន លោកថៅកែតាកាគី ក្រុមគ្រួសាររបស់រីន

**គ្មានអ្វីផ្លាស់ប្តូរនោះទេប្រសិនបើយើងមិនធ្វើអ្វីមួយនោះ**

ក្រុមហ៊ុនបានទទួលសិក្ខាកាមចំនួន៥ឆ្នាំមកហើយ។ ប៉ុន្តែ 「ចំនួនអ្នករត់មានច្រើនណាស់」 ។
លោកប្រធានបានបន្តថាការការពារការរត់ចោលកន្លែងការងារពិបាកនឹងទប់ស្កាត់ណាស់។តែបើមិនបញ្ចេញសកម្មភាពរកដំណោះស្រាយទេមិនអាចទទួលបានលិទ្ធផលនោះទេ។លោកក៏បានចាប់អារម្មណ៍ទៅលើសម្តីរបស់អ្នកទទួលបន្ទុកគ្រប់គ្រងថាមានលោកប្រធានមួយចំនួនបានចុះទៅមើលស្ថានភាពគ្រួសាររបស់សិក្ខាកាមផ្ទាល់។លោកក៏បានគិតពីការបារម្ភរបស់ម្តាយឪពុក (តើកូនរបស់ពួកគាត់ទៅធ្វើការជាមួយអ្នកណា ស្ថិតក្រោមអ្នកណា) ទើបអញ្ជើញទៅជួបផ្ទាល់ដើម្បីបង្កើនការទុកចិត្តជាវិធីសាស្ត្រមួយក្នុងការបង្ការការរត់ចោលកន្លែងការងារ។

**ដំណើរទស្សនកិច្ចទៅកាន់ផ្ទះសិក្ខាកាមពិតជាលំបាកណាស់**

ក្រុមហ៊ុនបានសម្ភាសន៍ជាប់សិក្ខាកាមចំនួន៣នាក់ហើយបានចុះទៅទស្សនកិច្ចទៅកាន់ផ្ទះរបស់ពួកគេ។គោលដៅនោះគឺនៅឆ្ងាយដោយធ្វើដំណើរតាមរថយន្តពីខេត្តងាណានចំនួន៤ម៉ោង, ធ្វើដំណើរតាមរថយន្តពីខេត្តហូជីងមិញចំនួន៨ម៉ោងហើយផ្លូវថ្នល់ក៏មិនអំណោយផលក្នុងការធ្វើដំណើរនោះទេ។ក៏ប៉ុន្តែកាលវិភាគពិតជាមមាញឹកណាស់។មកដល់វៀតណាមយប់ទទួលទានអាហាររួចប្រញាប់គេង។ព្រឹកឡើងត្រូវទៅសម្ភាសន៍,រួចរាល់ហើយក៏បន្តស្វែងរកផ្លូវជាមួយអ្នកបកប្រែដើម្បីចុះទៅផ្ទះរបស់សិក្ខាកាម។ដោយសារមួយថ្ងៃអាចទៅផ្ទះសិក្ខាកាមបានតែម្នាក់ដូច្នេះហើយមិនមានពេលធ្វើដំណើរកំសាន្តនោះទេ។ លោកប្រធានជាអ្នកទទួលរ៉ាប់រងរាល់ការចំណាយទាំងអស់ ។

**ពាក្យដែលត្រូវផ្តែផ្តាំទៅកាន់ឪពុកម្តាយ**

យើងនឹងឆ្លើយសំនួរទាំងអស់ដែលអ្នកបានសួរ។ពេលកូនលោកអ្នកមកដល់ប្រទេសជប៉ុនយើងនឹងមើលថែពួកគេជំនួសគាត់។បន្ទាប់មកក៏បានចាប់ដៃគ្នាបបួលគ្នាហូបស្រាបៀរចុងក្រោយបានពោលពាក្យថា ខ្ញុំពឹងលើលោកហើយ។លោកប្រធានក៏មានអារម្មណ៍ថា លោកត្រូវតែមានទំនួលខុសត្រូវ។លោកមានអាយុប្រហាក់ប្រហែលនឹងឪពុកម្តាយរបស់ពួកគេលោកយល់អារម្មណ៍របស់ពួកគាត់។ លោកបង្រៀនជំនាញដល់ពួកគេទើបប្រគល់ជូនឪពុកម្តាយវិញ។

**ចំណាប់អារម្មណ៍ពេលបានចុះទស្សនកិច្ចទៅកាន់ផ្ទះសិក្ខាកាម**

កន្លែងដែលបានទៅហាក់បីដូចជាប្រទេសជប៉ុន៥០、៦០ឆ្នាំមុនអញ្ចឹង។គ្រួសារកសិកររកប្រាក់មួយខែបាន១៥០ទៅ១៦០ដុល្លារក្នុងមួយខែ។ទីនោះមិនមែនជាកន្លែងទេសចរណ៍ទេប្រសិនបើចាប់យកជំនាញបាននោះពេលត្រលប់ទៅវិញអាចជួយសម្រួលដល់ជីវភាពមួយកំរិតទៀតមិនខាន។ រួមគ្នានេះដែរក៏បានសំណេះសំណាលជាមួយអ្នកជិតខាងផងដែរដោយបានប្រាប់ទៅថា (ថៅកែខ្ញុំបានចុះមកទស្សនកិច្ចផ្ទះខ្ញុំ)។ អ្នកខ្លះមិនស្គាល់ប្រទេសជប៉ុនមិនដឹងនៅទីណាជាដើម។ រួចក៏បានរៀបចំទទួលអាហារយ៉ាងកក់ក្តៅទៀតផង។

**បណ្តុះបណ្តាលធនធានជំនាញ**

ការទទួលយកមកបម្រើការងារមិនមែនមកពីប្រាក់ឈ្នួលថោកនោះទេ។ពួកគេគឺជាធនធានដ៏សំខាន់ក្រុមហ៊ុនមិនអាចអត់ការជ្រោមជ្រែងពីពួកគេបានទេ។អ្នកគ្រប់គ្រងត្រូវតែគិតដល់អនាគតនិងគ្រួសាររបស់ពួកគេ។ ៣ឆ្នាំក្រោយពួកគេចង់ត្រលប់មកធ្វើការម្តងទៀតក្នុងនាមជា សិក្ខាកាមជំនាញ ប្រសិនបើមិនមានសមត្ថភាពនោះទេយើងក៏មិនអាចផ្តល់ប្រាក់ខែអោយសមនឹងសមត្ថភាពនោះទេ។

លោកនឹងយកចិត្តទុកដាក់ក្នុងការបង្រៀនដោយសារតែលោកក៏ទៅការដ្ឋានដូចគ្នាពេលខុសថាខុសពេលត្រូវថាត្រូវដើម្បីការពារកុំអោយមានគ្រោះថ្នាក់ក្នុងការងារ។ពេលស្តីបន្ទោសគឺនិយាយដូចទឹកចិត្តឪពុកម្តាយអញ្ចឹង។ ឪពុកម្តាយមិនត្រូវថ្នមកូនពេកនោះទេ។

**លទ្ធិផលទទួលបានពីការចុះទស្សនកិច្ច**

បច្ចុប្បន្នសិក្ខាកាមដែលត្រូវបានថៅកែចុះទៅដល់ផ្ទះផ្ទាល់មិនទាន់មានអ្នករត់ចោលកន្លែងការងារនោះទេ។លោកបានបន្តទៀតថា យើងមិនអាចសន្និដ្ឋានថា វិធីសាស្ត្រចុះទស្សនកិច្ចទៅកាន់ផ្ទះសិក្ខាកាមនេះជាវិធីដែលត្រឹមត្រូវមានប្រសិទ្ធភាពនោះទេប៉ុន្តែលោកនិងបន្តធ្វើដដែល។ អ្វីដែលល្អបំផុតនោះគឺយើងត្រូវគិតពីអនាគតគ្នាទៅវិញទៅមក។

---

## សិក្ខាកាមទទួលបានការកោតសរសើរនៅក្នុងពិធីជួបជុំរបស់ក្រុមហ៊ុន

ថ្ងៃទី ២៨ ខែកក្កដា នៅក្នុង ក្រុង ហ្គេរូ ខេត្តហ្គីហ្វូ ក្នុងពិធីប្រកួតប្រជែងដែលប្រារព្ធឡើងដោយក្រុមហ៊ុនកាណេកុ លោកNGO VAN THANGនិង លោក DUONG MINH VU កំពុងតែធ្វើការផ្នែកវិស្វកម្មសំណង់ស៊ីវិលត្រូវបានទទួលការកោតសរសើរ។ព្រឹត្តិការណ៍នេះប្រារព្ធធ្វើឡើងជារៀងរាល់ឆ្នាំដោយទទួលការចូលរួមពីក្រុមហ៊ុនក្នុងសម្ព័ន្ធកាណេកុក្នុងនោះដែរមានសិក្ខាសាលាស្តីពីសុវត្ថិភាពនិងវិធីផ្តល់ប័ណ្ណសរសើរជូនដល់បុគ្គលិកឆ្នើមផងដែរ។អ្នកទាំង២ត្រូវបានគេទទួលស្គាល់នឹងសរសើរលើការយល់ដឹងស៊ីជម្រៅអំពីសុវត្ថិភាព។




លោកNGO VAN THANGទទួលប័ណ្ណសរសើរ

## សិក្ខាកាមចំនួន១១នាក់បានជាប់ការប្រលងសមត្ថភាពជំនាញភាសាជប៉ុន

សិក្ខាកាមហ្វឹកហាត់ជំនាញចំនួន១១នាក់ដែលធ្វើការនៅក្រុមហ៊ុនក្នុងសហជីពបានជាប់ការប្រលងសមត្ថភាពភាសាជប៉ុនលើកទី១ដែលបានធ្វើឡើងនៅឆ្នាំ ២០១៩ ថ្ងៃទី៧ ខែកក្កដា (ថ្ងៃអាទិត្យ) ។ សិស្សដែលបានប្រលងជាប់កំរិតN2 បានទទួលប្រាក់ចំនួន ៣0,000 យ៉េនជាអំណោយអបអរសាទរពីសហជីព ។ កាលបរិច្ឆេទប្រលងបន្ទាប់គឺថ្ងៃទី ១ ខែធ្នូ (ថ្ងៃអាទិត្យ) ។

【កំរិតN2】 3នាក់ 【កំរិតN3】 6នាក់ 【កំរិតN4】 2នាក់




លោក NGUYEN VAN VUI ជាអ្នកដែលជាប់កំរិតN 2 (ក្រុមហ៊ុនលាបថ្នាំ កាវ៉ាតាបាក់)ការសរសេរដោយដក់នៅផ្នែកខាងក្រោយគឺលោកជាអ្នកសរសេរដោយផ្ទាល់។



ការប្រកួតបាល់ទាត់លើកទី២ ឧបត្ថម្ភដោយសាខាខាន់សៃ (ថ្ងៃទី២០ខែ១០)